**សិក្ខាសាលាចាប់ផ្តើមការរៀបចំក្របខណ្ឌហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ និង**
**ផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅតាមក្រសួង-ស្ថាប័នពាក់ព័ន្ធ**
**ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៣**
**សណ្ឋាគារ ហ៊ីម៉ាវ៉ារី ភ្នំពេញ កម្ពុជា**

# សុន្ទរកថាស្វាគមន៍របស់ឯកឧត្តម នុត ច័ន្ទសុខា អនុរដ្ឋលេខាធិការក្រសួងផែនការ និងជាសមាជិកគណៈកម្មាធិការជាតគ្រប់គ្រងការប្រែប្រួលអាកាសធាតុ

សូមគោរព

- ឯកឧត្តម ធឹក គ្រឿនវុត្ថា រដ្ឋលេខាធិការក្រសួងបរិស្ថាន តំណាងឯកឧត្តមបណ្ឌិត ម៉ុក ម៉ារ៉េត ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ
- ឯកឧត្តម ហ្សង់ ហ្វ្រង់ស្វ័រ កូតាំង ឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុបប្រចាំកម្ពុជា
- ឯកឧត្តម លោកជំទាវ ជាសមាជិកគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ
- ភ្ញៀវកិត្តិយស លោក លោកស្រី សមាជិកអង្គសិក្ខាសាលាជាទីមេត្រី

ថ្ងៃនេះខ្ញុំមានកិត្តិយស និងសេចក្តីរីករាយជាអនេកប្បការ ដែលបានទទួលការអញ្ជើញឲ្យមកចូលរួមនៅក្នុងពិធីបើក *សិក្ខាសាលាចាប់ផ្តើមការរៀបចំក្របខណ្ឌហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ និងផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅតាមក្រសួង–ស្ថាប័នពាក់ព័ន្ធ* និងថ្លែងសុន្ទរកថាស្វាគមន៍តំណាងឲ្យក្រសួងផែនការ។

ការប្រែប្រួលអាកាសធាតុគឺជាកត្តាខាងក្រៅចំបងមួយ ដែលចាំបាច់ត្រូវតែគិតគូរ នៅពេលយើងកំណត់លំនាំនៃការអភិវឌ្ឍសម្រាប់កម្ពុជានៅក្នុងរយៈពេលវែង។ ការសម្រេចរបស់យើងនៅថ្ងៃនេះអំពីការវិនិយោគត្រូវគិតអំពីឱកាស ក៏ដូចជាការគំរាមកំហែង ដែលបង្កដោយការប្រែប្រួលអាកាសធាតុផងដែរ ដើម្បីយើងអាចសម្រេចផលប្រយោជន៍ខាងសង្គម និងសេដ្ឋកិច្ចជាអតិបរមា នាពេលបច្ចុប្បន្ន និងទៅអនាគត។

រាជរដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់ប្រការនេះយ៉ាងពេញលេញ។ កន្លងមក ការប្រែប្រួលអាកាសធាតុគឺជាផ្នែកដ៏សំខាន់មួយនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ ហើយបច្ចុប្បន្នការងារប្រែប្រួលអាកាសធាតុបានក្លាយទៅជាបញ្ហាអន្តរវិស័យចំបងមួយ នៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨។ ដោយសារតែកិច្ចខិតខំប្រឹងប្រែងរបស់សមាជិកគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ និងក្រុមបច្ចេកទេសការងារប្រែប្រួលអាកាសធាតុនៅតាមក្រសួង-ស្ថាប័ននានា អាទិភាពនៃការប្រែប្រួលអាកាសធាតុត្រូវបានដាក់បញ្ចូលយ៉ាងមានប្រសិទ្ធភាព នៅក្នុងធាតុចូលរបស់ក្រសួងនានាដែលក្រសួងផែនការបានទទួល ក្នុងអំឡុងពេលប៉ុន្មានសប្តាហ៍កន្លងទៅនេះ ដែលនេះជាមូលដ្ឋានសម្រាប់

សេចក្តីព្រាងដំបូងនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិថ្មីមួយ។ ដូចដែលយើងទាំងអស់គ្នាដឹងស្រាប់ហើយ ការពិគ្រោះយោបល់ជាច្រើនលើកត្រូវបានគ្រោងធ្វើ សម្រាប់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ នៅចុងឆ្នាំនេះ ហើយខ្ញុំមានជំនឿជឿជាក់ថា ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលមានវត្តមាននៅទីនេះ នឹងរួមចំណែកយ៉ាងសកម្ម ដើម្បីធានាថា អាទិភាពប្រែប្រួលអាកាសធាតុ ដូចដែលមានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុនៃក្រសួង-ស្ថាប័ននានា នឹងត្រូវបានដាក់បញ្ចូលយ៉ាងទូលំទូលាយនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដែលជាឯកសារផែនការជាតិសំខាន់មួយសម្រាប់រយៈពេល ៥ ឆ្នាំខាងមុខ។

ជំហានបន្ទាប់គឺត្រូវឆ្លុះបញ្ចាំងអាទិភាពទាំងនេះនៅក្នុងផែនការវិនិយោគ នៅក្នុងថវិកា និងក្នុងរបៀបរបបលើកផែនការ និងអនុវត្តកម្មវិធីអភិវឌ្ឍន៍នានា។ កិច្ចការដែលកំពុងប្រកាសចាប់ផ្តើមថ្ងៃនេះ នឹងដើរតួនាទីយ៉ាងសំខាន់នៅក្នុងជំហានបន្ទាប់ទាំងនេះ។ កិច្ចការនេះនឹងរក្សាចំណាងទាក់ទងនៃអាទិភាពធំៗ ដែលមានចែងនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ជាមួយជំហានលំអិតនានា ដែលត្រូវអនុវត្ត ដើម្បីប្រតិបត្តិការផែនការនោះ។

កិច្ចការថ្ងៃនេះនឹងផ្តល់ឲ្យយើងទាំងអស់គ្នានូវវិធីសាស្ត្រ សម្រាប់កំណត់អំពីការចំណាយ ដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ ដើម្បីចាត់ជាអាទិភាពនូវការចំណាយទាំងនោះ ដោយផ្អែកតាមយុទ្ធសាស្ត្រនានារបស់យើង និងដើម្បីកំណត់នូវយន្តការអនុវត្តដែលសមស្រប។

ដូចដែលយើងដឹងហើយថា ការប្រែប្រួលអាកាសធាតុមិនមែនជាបញ្ហាតាមវិស័យដោយឡែកណាមួយឡើយ តែវាជាបញ្ហាអន្តរវិស័យ ដែលត្រូវពិចារណា នៅក្នុងពេលយើងគ្រោងសកម្មភាពអភិវឌ្ឍន៍ជាប្រក្រតី។ ឧទាហរណ៍ ប្រសិនបើមានការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ ឬកម្មវិធីកសិកម្ម ដោយគ្មានពិចារណាអំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ដូចជាកំណើនសីតុណ្ហភាព ឬព្រឹត្តិការណ៍អាកាសធាតុធ្ងន់ធ្ងរមិនប្រក្រតី នោះការវិនិយោគអាចនឹងនាំមកនូវផលប្រយោជន៍ខាងសង្គម និងសេដ្ឋកិច្ចតិចជាងមុន ហើយយើងត្រូវបង្ខំចិត្តធ្វើការវិនិយោគកាន់តែច្រើនទៅអនាគត ដើម្បីដោះស្រាយផលវិបាកទាំងនេះ។ ដូចគ្នានេះដែរ ការប្រែប្រួលអាកាសធាតុក៏អាចផ្តល់ឱកាសខ្លះៗ ហើយយើងក៏គួរតែសិក្សាឱកាសទាំងនោះដោយប្រុងប្រយ័ត្ន ដើម្បីយើងអាចវិនិយោគលើសកម្មភាពត្រឹមត្រូវ ដែលនឹងនាំមកនូវផលប្រយោជន៍ជាអតិបរមាខាងសង្គម និងសេដ្ឋកិច្ច នៅក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ។

ក្នុងន័យនេះ យើងចាំបាច់ត្រូវមានយន្តការហិរញ្ញប្បទានមួយ ដែលអាចឲ្យយើងដាក់បញ្ចូលគ្នានូវមូលនិធិអភិវឌ្ឍន៍ជាធម្មតា និងហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ នៅក្នុងវិធានការឆ្លើយតបចម្រុះ។ នេះប្រការចាំបាច់សម្រាប់ហិរញ្ញប្បទានពីក្រៅប្រទេស ប៉ុន្តែវាក៏មានសារៈសំខាន់ផងដែរសម្រាប់ធនធានក្នុងប្រទេស។ កម្ពុជាកំពុងអភិវឌ្ឍន៍យ៉ាងឆាប់រហ័ស ផលចំណូលក្នុងប្រទេសរបស់យើងក៏កើនឡើងជារៀង

រាល់ឆ្នាំផងដែរ ហើយក្នុងពេលឆាប់ៗខាងមុខនេះ យើងនឹងឈានទៅកាន់ស្ថានភាពជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាប។ នេះមានន័យថា យើងត្រូវតែបញ្ជ្រាបការប្រែប្រួលអាកាសធាតុ មិនត្រឹមតែនៅក្នុងភាពជាដៃគូជាមួយម្ចាស់ជំនួយរបស់យើងប៉ុណ្ណោះទេ ប៉ុន្តែប្រការសំខាន់ជាងនេះទៀត គឺនៅក្នុងការកសាងផែនការ និងការលើកថវិកាផ្ទៃក្នុងរបស់យើង។

ភារៈកិច្ចនេះមិនមែនជាកិច្ចការងាយស្រួលនោះឡើយ ហើយអ្វីដែលយើងប្រកាសចាប់ផ្តើមធ្វើថ្ងៃនេះ គឺជាមូលដ្ឋានគ្រឹះសម្រាប់កិច្ចការជាច្រើនផ្សេងទៀត។ វិធីសាស្ត្រ និងមធ្យោបាយថ្មីៗមួយចំនួន នឹងត្រូវយកមកអនុវត្តសាកល្បង នៅក្នុងការកសាងផែនការសកម្មភាពនេះ។ មហិច្ឆិតារបស់យើងគឺដើម្បីឲ្យកម្ពុជាក្លាយជាគំរូមួយ សម្រាប់វិធីសាស្ត្រជាយុទ្ធសាស្ត្របែបនេះ និងដើម្បីផ្តល់មេរៀន ក៏ដូចជារបៀបប្រតិបត្តិល្អៗ ដែលអាចបញ្ចូលទៅក្នុងការពិភាក្សានៅកម្រិតពិភពលោកអំពីការកសាងផែនការ និងយន្តការហិរញ្ញប្បទានប្រែប្រួល អាកាសធាតុ។

ក្នុងនាមក្រសួងផែនការ ខ្ញុំសូមថ្លែងអំណរគុណដ៏ស្មោះស្ម័គ្រចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ ដែលបានខិតខំប្រឹងប្រែងសម្រេចបាននូវសមិទ្ធិផលគួរជាទីពេញចិត្ត ក្នុងការដាក់បញ្ចូលការងារប្រែប្រួលអាកាសធាតុទៅក្នុងផែនការយុទ្ធសាស្ត្រនៅក្នុងបណ្តាក្រសួង-ស្ថាប័នរបស់ខ្លួន ហើយខ្ញុំរំពឹងថា ឯកឧត្តម លោកជំទាវ លោក លោកស្រី នឹងបន្តចូលរួមក្នុងការអនុវត្តកិច្ចការនេះបន្តទៀត សំដៅប្រែក្លាយផែនការយុទ្ធសាស្ត្រ ឲ្យទៅជាផែនការវិនិយោគសាធារណៈ និងថវិកាជាក់លាក់។

សូមអរគុណ !